ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខៈ ១៤៨/១៦ គ.សាង

**កំណត់ហេតុ**
**ពិធីសណេះសំណាលស្វែងយល់អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា**
**រវាងតំណាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា**
**និងលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
សាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែតុលា ថ្ងៃទីបួន វេលាម៉ោង ប្រាំបួនព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) មានពិធីសណេះសំណាលស្តីពីការ ស្វែងយល់អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា រវាងតំណាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។

ជាកិច្ចចាប់ផ្តើម លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅ និងបានធ្វើការណែនាំខ្លួន និងសមាសភាពដែលបានអញ្ជើញចូលរួមនាពេលនេះ បន្ទាប់មកខាងតំណាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ធ្វើការណែនាំខ្លួន សមាសភាពតួនាទីភារកិច្ចផងដែរ។

បន្ទាប់ពីធ្វើការណែនាំខ្លួនទៅវិញទៅមករួចមក **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មានប្រសាសន៍ទាក់ទងទៅនឹងសកម្មភាពការងារចម្បងៗ និងការងារប្រចាំថ្ងៃ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ។ **លោកជំទាវ**បានបន្ថែមទៀតថា ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មិនអាចធ្វើតែម្នាក់ឯងបានទេ ត្រូវទាមទារឲ្យមានការសហការគ្នាពីគ្រប់មជ្ឈដ្ឋាន គ្រប់ទិសទី ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូនានា និងមានការសហការគ្នារវាងប្រទេស និងប្រទេសនៅក្នុងតំបន់ ក៏ដូចជានៅលើសកលលោក ដើម្បីរួមគ្នាបង្ការ ទប់ស្កាត់នូវអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារ។ **លោកជំទាវ** មានប្រសាសន៍ដោយសង្ខេបអំពីរចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ រហូតដល់មូលដ្ឋាន និងក្រុមការងារទាំងប្រាំមួយ ដែលបានចូលរួមសហការពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន យើងមានគោលនយោបាយជាតិ និងយុទ្ធសាស្ត្រ នៃការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សនៅកម្ពុជា។

មតិលោក Ben Jamin Skinner (Visiting Scholar) លោកបានសំដែងការអបអរសាទរចំពោះចំណាត់ថ្នាក់ទាក់ទងការជួញដូរមនុស្សនៅកម្ពុជា ដែលបានទទួលនូវលទ្ធផលល្អប្រសើរបើប្រៀបធៀបទៅនឹងនៅក្នុង

តំបន់មួយចំនួន។ វាជាការចាំបាច់ណាស់ក្នុងការសហការគ្នា ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ប៉ុន្តែយើងសង្កេតឃើញថាការជួញដូរមនុស្សមានការថយចុះជាលំដាប់គួរឲ្យកត់សម្គាល់។ ដោយឡែកនៅប្រទេសកម្ពុជាវិញបានទទួលចំណាត់ថ្នាក់លេខពីរ នៃការវាយតម្លៃពីសហរដ្ឋអាមេរិក តែវាមិនទាន់បានល្អនៅឡើយ យើងចង់បានចំណាត់ថ្នាក់លេខមួយ។ លោក Ben Jamin Skinner បានមានមតិទាក់ទងទៅនឹងការជួញដូរមនុស្ស ឲ្យមានការចូលរួមពីបណ្តាវិស័យឯកជន អ្នកជំនួញ អ្នកធ្វើអាជីវកម្មផ្សេងៗ ត្រូវធ្វើការទាក់ទាញដើម្បីឲ្យពួកគាត់ចូលរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពីព្រោះវិស័យឯកជន អ្នកធ្វើអាជីវកម្ម អ្នកជំនួញ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការចូលរួមគាំទ្រដើម្បីធ្វើការបង្ការ ទប់ស្កាត់ នូវអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្មជាដើម។ លោក Ben Jamin Skinner មានមតិទាក់ទងទៅនឹងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីសហរដ្ឋអាមេរិកនាពេលខាងមុខនេះ ប្រសិនបើលោកស្រី ហ៊ីឡារី គ្លីនតុន នៃគណៈបក្សប្រជាធិបតេយ្យជាប់ឆ្នោតជាប្រធានាធិបតី លោកស្រីនឹងផ្តោតសំខាន់ទៅលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាការងារអទិភាព និងជាពិសេសប្រទេសកម្ពុជា លោកស្រីធ្លាប់បានមកធ្វើទស្សនៈកិច្ចរួចមកហើយ ហើយលោកស្រីធ្លាប់បានជួបជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្សផងដែរ។ ចុងបញ្ចប់ លោក Ben Jamin Skinner បានសួរសំនួរថា **តើរាជរដ្ឋាភិបាលកម្ពុជាមានគោលបំណង ផ្តោតទៅលើវិស័យឯកជន អ្នកវិនិយោគ អ្នកជំនួញ មកចូលរួមសហការក្នុងការងារ ទប់ស្កាត់ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែរទេ?**

**លោកជំទាវ ជូ ប៊ុនអេង** មានប្រសាសន៍ទាក់ទងទៅនឹងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីសហរដ្ឋអាមេរិក បើលោកស្រី ហ៊ីឡារី គ្លីនតុន ជាប់ជាប្រធានាធិបតី ខ្ញុំមានការសប្បាយរីករាយជាខ្លាំង មិនមែនខ្ញុំជាស្ត្រីដូចគ្នាទេ តែវាជាការពាក់ព័ន្ធទៅនឹងមនុស្សជាតិ។ **លោកជំទាវ** មានប្រសាសន៍ឆ្លើយតបនឹងសំនួររបស់លោក Ben Jamin Skinner ថារាជរដ្ឋាភិបាលកម្ពុជាផ្តោតសំខាន់ទៅលើការជួញដូរមនុស្ស ដែលមានការចូលរួមសហការពីបណ្តាក្រសួង ស្ថាប័ន និងវិស័យឯកជនក្នុងការជួយជ្រោមជ្រែង គាំទ្រ ក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលកំសាន្តសម្រាប់មនុស្សចាស់គឺមិនត្រូវបានអនុញ្ញាតិឲ្យយុវវ័យអាយុក្រោមដប់ប្រាំបីឆ្នាំចូលឡើយ ហើយបានធ្វើកិច្ចសន្យាជាមួយសណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត ខារ៉ាអូខេ ម៉ាស្សា-កោសជប់ និងកន្លែងកំសាន្តនានាមួយចំនួនទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតិ ឬបង្កប់ លួចលាក់សេវាផ្លូវភេទ អំពើពេស្យាចារលើស្ត្រី និងកុមារនៅក្នុងនោះឡើយ ហើយបានប្រគល់ភារកិច្ចទាំងអស់នេះឲ្យ ក្រសួងទេសចរណ៍ជាអ្នកគ្រប់គ្រង នេះគឺជាការចូលរួមពីវិស័យឯកជន។ **លោកជំទាវ** បានបន្តថា ការទប់ស្កាត់អំពើជួញដូរមនុស្ស ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា បញ្ចូលទៅក្នុងកម្មវិធីអប់រំ សិក្សា នៅតាមបណ្តាគ្រឹះស្ថានសិក្សានានាចាប់ពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់មធ្យមសិក្សាផងដែរ។

ចុងបញ្ចប់ នៃពិធីសំណេះសំណាល លោក Ben Jamin Skinner មានមតិថ្លែងអំណរគុណចំពោះ**លោកជំទាវ** និងក្រុមការងារ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដែលបានចំណាយពេលវេលាដ៏មានតំលៃក្នុងការជួបសំណេះសំណាល និងផ្លាស់ប្តូរនូវបទពិសោធន៍ការងារពាក់ព័ន្ធនឹង

អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ និងគោរពជូនពរ លោកជំទាវ និងក្រុមការងារមានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច។ បន្ទាប់មក លោកជំទាវ អនុប្រធាន អចិន្ត្រៃយ៍ មានប្រសាសន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក Ben Jamin Skinner និងក្រុមការងារ តំណាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានចំណាយពេលវេលាមានតម្លៃ មកជួប ពិភាក្សា សំណេះសំណាល និងផ្តល់បទពិសោធន៍ដ៏មានអត្ថន័យទៅវិញទៅមក។ លោកជំទាវ បានជូនពរចំពោះ លោក Ben Jamin Skinner និងក្រុមការងារទទួលបានជោគជ័យគ្រប់ភារកិច្ច។

ពិធីសំណេះសំណាលបានបញ្ចប់នៅវេលាម៉ោង ដប់ និងដាប់ប្រាំនាទីព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែល។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦

**អ្នកធ្វើកំណត់ហេតុ**

(signature)

**គោរពជូន**

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៦

ប្រធានលេខាធិការដ្ឋាន

(signature)

10/10/2016

# សមាសភាពចូលរួម
# ពិធីសណេះសំណាលស្វែងយល់អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា
# រវាងតំណាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា
# និងលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

សាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦

| | | |
|---|---|---|
| ១.លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| ២.ឯ.ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៣.លោក | E.Benjamine Skinner | Visiting Scholar |
| ៤.លោក | David Josar | International Officer ( US Embassy ) |
| ៥.ឯ.ឧ.ទោ | ស៊ុន វ៉ូ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៦.ល.ឧ.ទោ | ប៊ុណ្ណ សំខាន់ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៧.ឯ.ឧ.ទោ | ខៀវ ចាន់ប៉ា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៨.លោក | Eng Po | Public Affair ( US Embassy ) |
| ៩.លោក | Oun Chanpanhara | Pol/Eum ( US Embssay ) |
| ១០.លោក វ.ឯក | ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១១.លោក | សៅ ស៊ីនួន | មន្ត្រីកំណត់ហេតុ គ.ជ.ប.ជ |

សរុបចំនួន: ១១ រូប, ស្រីចំនួន ០២ រូប